ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៤១៥.....សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មអំណាចជូន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត-ក្រុង

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ ស្តីពីការបង្កើតអនុគណៈកម្មាធិការវិនិយោគ ខេត្ត-ក្រុង លេខ ១៥ ដល់ ៣៨ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៥
- បានឃើញលិខិតលេខ ៨៣៤/០៥ ក.អ.ក ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីការធ្វើវិសហមជ្ឈការ អំណាចជូនក្រសួងមន្ទីរ អង្គភាពក្រោមឱវាទ ខេត្ត-ក្រុង

## សំរេច

**ប្រការ ១:** ធ្វើប្រតិភូកម្មអំណាចជូនប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត-ក្រុង ទាំងអស់ នូវសិទ្ធិសំរេចលើការងារវិនិយោគ ខេត្ត-ក្រុង ដែលមានទឹកប្រាក់ទាបជាង ២ លានដុល្លារអាមេរិក ស្របតាមបទបញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានជាធរមាន ជួសមុខអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការចូលរួម ផ្តល់យោបល់ក្នុងក្របខ័ណ្ឌបច្ចេកទេស និងទទួលខុសត្រូវរាល់ការសំរេចពាក់ពន្ធ័នឹងការផ្តល់គោលការណ៍វិនិយោគ ជូនបណ្តាក្រុមហ៊ុនវិនិយោគនានា ក្នុងក្របខណ្ឌ័សមាជិកអនុគណៈកម្មាធិការវិនិយោគ ខេត្ត-ក្រុង និងក្នុងនាមជាអ្នកអនុវត្តប្រតិភូកម្មអំណាច។

**ប្រការ ២:** ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត-ក្រុង ចូលរួមរាល់កិច្ចប្រជុំពិនិត្យដោះស្រាយ គំរោងវិនិយោគនិមួយៗទៅតាមការកោះអញ្ជើញរបស់អនុគណៈកម្មាធិការវិនិយោគ ខេត្ត-ក្រុង អមដោយប្រធានសាខាគយនិងរដ្ឋាករ និងប្រធានសាខាពន្ធដារតាម ខេត្ត-ក្រុង រៀងៗខ្លួន ។ ក្នុងករណីមិនបានចូលរួមប្រជុំដោយផ្ទាល់ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត-ក្រុង ចាំបាច់ត្រូវចាត់តាំងតំណាងដែលមានសិទ្ធិសំរេចអោយចូលរួមប្រជុំជំនួស។

**ប្រការ ៣:** ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត-ក្រុង ទាំងអស់ ត្រូវពង្រឹងកិច្ចសហការតាមខ្សែទទឹងជាមួយគ្រប់មន្ទីរជំនាញនៅខេត្ត-ក្រុង របស់ខ្លួន ក្នុងក្របខ័ណ្ឌជាអង្គភាពសំរបសំរួលទស្សនៈគោលនយោបាយសេដ្ឋកិច្ចជូនអនុគណៈកម្មាធិការវិនិយោគ ខេត្ត-ក្រុង។

**ប្រការ ៤:** ស្តីពីមតិយោបល់របស់ខ្លួន ដែលបានចូលរួមក្នុងការប្រជុំ ពិនិត្យសំរេច របស់អនុគណៈកម្មាធិការវិនិយោគ ខេត្ត-ក្រុង ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍អោយច្បាស់លាស់ និងទៀងទាត់ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអគ្គលេខាធិការដ្ឋានរបស់ក្រសួង។

**ប្រការ ៥:** ក្នុងករណីមិនច្បាស់លាស់អំពីគោលការណ៍ ឬ សេចក្តីណែនាំនានា ដែលពាក់ពន្ធ័នឹងការងាររបស់អនុគណៈកម្មាធិការវិនិយោគ ខេត្ត-ក្រុង ពាក់ពន្ធ័នឹងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរាយការណ៍មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីសុំការណែនាំជាមុនសិន។

**ប្រការ ៦:** រាល់បទបញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧:** អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានសាខាគយ និងរដ្ឋាករ ប្រធានសាខាពន្ធដារ គ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែ សីហា ឆ្នាំ ២០០៥

គាត ឈន់

**<u>ចម្លងជូន</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន និង ខេត្ត-ក្រុង
- អនុគណៈកម្មាធិការវិនិយោគខេត្ត-ក្រុង
- គ្រប់ថ្នាក់ដឹកនាំនៃ កសហវ
  "ដើម្បីជ្រាបជាពត៌មាន"
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ